ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៣៩ សហវ.គ.ស.ក.អគក

# សេចក្តីសម្រេច
## ស្តីពី
## ការដាក់ឱ្យអនុវត្តសាកល្បងនូវគម្រោងធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញ អនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញ អនុក្រឹត្យលេខ ១៤៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញ អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia
nspc.gov.kh / t.me/socialprotectionkh
ទូរស័ព្ទលេខ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone : (+855) 23 890 666
gs_nspc@mef.gov.kh

- បានឃើញ សេចក្តីសម្រេចលេខ ០០៣ សហវ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- យោងតាមការចាំបាច់របស់ក្រុមប្រឹក្សាជាតិគាំពារសង្គម

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

សេចក្តីសម្រេចនេះមានគោលបំណងដាក់ឱ្យអនុវត្តសាកល្បងនូវគម្រោងធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម ដើម្បីពិនិត្យ និងវាយតម្លៃលើលទ្ធភាពក្នុងការធ្វើសុខដុមនីយកម្ម និងឈានទៅធ្វើការផ្លាស់ប្តូរទិន្នន័យនៃប្រព័ន្ធចុះបញ្ជី ឬប្រព័ន្ធព័ត៌មានវិទ្យាក្នុងក្របខណ្ឌគាំពារសង្គម។

**ប្រការ ២.-**

សេចក្តីសម្រេចនេះមានវិសាលភាពគ្របដណ្តប់លើគម្រោងសាកល្បងធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម ដោយប្រើប្រាស់ទិន្នន័យចុះបញ្ជីចំនួន១០ ០០០ នាក់ នៃប្រព័ន្ធអេឡិចត្រូនិចកត់ត្រា និងគ្រប់គ្រងទិន្នន័យអ្នកជំងឺ នៃទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល, ប្រព័ន្ធព័ត៌មានគាំពារសុខភាពសង្គម នៃបេឡាជាតិសន្តិសុខសង្គម, ប្រព័ន្ធកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ នៃមូលនិធិជាតិជំនួយសង្គម, ប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៃក្រសួងផែនការ, និងការផ្ទៀងផ្ទាត់ទិន្នន័យដោយប្រើប្រាស់ទិន្នន័យនៃប្រព័ន្ធអត្តសញ្ញាណបណ្ណប្រជាជននៅស្រុកជើងព្រៃ នៃខេត្តកំពង់ចាម និងក្រុងសៀមរាប នៃខេត្តសៀមរាប។

## ជំពូកទី២

## ការចូលរួមអនុវត្តគម្រោងរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ

**ប្រការ ៣.-**

ការអនុវត្តសាកល្បងនូវគម្រោងធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម ប្រើប្រាស់យន្តការស្ថាប័នរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម និងមានការចូលរួមដោយក្រសួងមហាផ្ទៃ, ក្រសួងផែនការ, ក្រសួងសុខាភិបាល, មូលនិធិជាតិជំនួយសង្គម, បេឡាជាតិសន្តិសុខសង្គម, ទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល ក្រោមការសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម និងជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។



4

**ប្រការ ៤.-**

ក្រសួង-ស្ថាប័នដែលចូលរួមអនុវត្តសាកល្បងនូវគម្រោងធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គមនេះ ត្រូវធ្វើការតភ្ជាប់, ផ្លាស់ប្តូរ, និងផ្ទៀងផ្ទាត់ទិន្នន័យចុះបញ្ជីសមាជិក, ប្រជាជនក្រីក្រ, ប្រជាជនងាយរងគ្រោះ, និងអត្តគាហក នៃប្រព័ន្ធចុះបញ្ជីដែលមានស្រាប់ ជាមួយនឹងមូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម។

ទិន្នន័យដែលជាកម្មវត្ថុនៃការផ្លាស់ប្តូរ និងផ្ទៀងផ្ទាត់ត្រូវមានភាពត្រឹមត្រូវ និងពេញលេញ។

**ប្រការ ៥.-**

មូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គមបង្កើត និងផ្តល់លេខសម្គាល់គាំពារសង្គមបុគ្គល ១០(ដប់) ខ្ទង់ សម្រាប់ការចុះបញ្ជី។

## ជំពូកទី៣
## ការប្រើប្រាស់ទិន្នន័យ និងការរក្សាការសម្ងាត់ទិន្នន័យ

**ប្រការ ៦.-**

រាល់ទិន្នន័យអត្តសញ្ញាណចុះបញ្ជី ដែលត្រូវប្រើប្រាស់សម្រាប់ការអនុវត្តសាកល្បងនូវគម្រោងធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម ជាកម្មវត្ថុនៃការរក្សាការសម្ងាត់។

ក្រសួង-ស្ថាប័នដែលចូលរួមក្នុងការអនុវត្តត្រូវរក្សាទុក និងប្រើប្រាស់លេខសម្គាល់គាំពារសង្គម ដូចមានចែងក្នុងប្រការ៥ នៃសេចក្តីសម្រេចនេះ។

**ប្រការ ៧.-**

មានតែក្រសួង- ស្ថាប័នចូលរួមការអនុវត្តគម្រោង ដូចមានក្នុងប្រការ ៣ ប៉ុណ្ណោះ ដែលមានសិទ្ធប្រើប្រាស់រាល់ទិន្នន័យដែលបានផ្តល់ការអនុញ្ញាតដោយក្រសួង- ស្ថាប័នសាមី សម្រាប់ការអនុវត្តគម្រោងសាកល្បងនេះ។

## ជំពូកទី៤
## កាលបរិច្ឆេទនៃការអនុវត្តគម្រោងសាកល្បង

**ប្រការ ៨.-**

ការអនុវត្តសាកល្បងនូវគម្រោងធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គមនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣។ កាលបរិច្ឆេទនៃការអនុវត្តអាចប្រែប្រួលយោងតាមស្ថានភាពចាំបាច់ជាក់ស្តែង។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ ៩.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៧ កើត ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ មីនា ឆ្នាំ ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងផែនការ
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ